

ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីឆ្នាំ២០២០

# សេចក្ដីណែនាំសម្រាប់អ្នកបោះឆ្នោត

SEARAC

## បង្កើតសម្រាប់គោលបំណងសិក្សាអប់រំតែប៉ុណ្ណោះ

**SEARAC** (សៀរ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង **(SEAA)**។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ **SEARAC** មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។។




# ភាពសមភាពនៃទិន្នន័យ និង ការបែងចែកទិន្នន័យ

## Joe Biden (D)

“ នៅឆ្នាំ ២០១៦ រដ្ឋបាលអូបាម៉ា - បៃដិនបានចាប់ផ្តើមគំនិតផ្តួចផ្តើមការបែងចែកទិន្នន័យរបស់ជនជាតិអាស៊ីអាមេរិចកាំងនិងជនជាតិនៅកោះតំបន់ប៉ាស៊ីហ្វិក ដែលជាកម្មវិធីជំនួយមួយដែលគេបានធ្វើការជាមួយរដ្ឋ “ ដើម្បីកែលម្អការប្រមូលទិន្នន័យ សម្រាប់ជួយបង្ហាញអំពីគម្លាតនៃឱកាសក្នុងការសិក្សា និងផ្តល់ការគាំទ្រដើម្បីឲ្យមានការរីកចម្រើនក្នុងការត្រៀមខ្លួនចូលរៀននៅមហាវិទ្យាល័យនិងត្រៀមខ្លួនចូលអាជីពសម្រាប់និស្សិតជនជាតិអាស៊ីអាមេរិចកាំងនិងជនជាតិនៅកោះតំបន់ប៉ាស៊ីហ្វិក  និងអ្នកសិក្សាភាសាអង់គ្លេសដែលមិនសូវទទួលបានសិទ្ធ។" កម្មវិធីនេះបានអនុវត្តតាមការផ្តួចផ្តើមនៅឆ្នាំ ២០១២ ពីរដ្ឋបាលអូបាម៉ា - បៃដិនដែលបានខិតខំស្នើសុំសាលារៀននិងស្ថាប័នឧត្តមសិក្សាឲ្យចែករំលែកការបែងចែកទិន្នន័យរបស់ពួកគេ។ ក្នុងនាមជាប្រធានាធិបតី ខ្ញុំនឹងប្តេជ្ញាចិត្តម្តងទៀតចំពោះការខិតខំទាំងនេះ និងធានាថាភ្នាក់ងាររបស់សហព័ន្ធនិងកម្មវិធីពាក់ព័ន្ធនឹងសហព័ន្ធទទួលបានទិន្នន័យត្រឹមត្រូវស្តីពីសហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង ព្រមទាំងធានាថាព័ត៌មានទាំងនោះត្រូវបានវិភាគនិងត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ដើម្បីធានាថាសហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំងកំពុងទទួលបានធនធាននិងការគាំទ្រយ៉ាងគ្រប់គ្រាន់។ ”

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

ទំនាក់ទំនង៖ searac@searac.org

SEARAC (សៀរ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នា ដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ SEARAC មិនគាំទ្របុប្រឆាំងបេក្ខជនមួយណាទេ។



# ការគាំទ្រផ្នែកវប្បធម៌ចំពោះថ្នាក់មត្តេយ្យដល់ថ្នាក់ទី១២

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

## Joe Biden (D)

ខ្ញុំបានស្នើថវិកាសម្រាប់ចំណងជើងទី ១ (Title I)ចំនួនគុណនឹងបីសម្រាប់សាលាដែលកំពុងបម្រើកុមារជាច្រើនពីគ្រួសារដែលមានប្រាក់ចំណូលទាប។ ថវិកាមូលនិធិថ្មីនេះជាដំបូងត្រូវប្រើ ដើម្បីធានាថាគ្រូនៅសាលាចំណងជើង ១ (Title I) ទទួលបានប្រាក់ចំណូលខ្ពស់សមរម្យ, ក្មេងអាយុពី ៣ ទៅ ៤ ឆ្នាំមានលទ្ធភាពចូលរៀនសាលាមតេយ្យ, ហើយស្រុក/សង្កាត់ផ្ដល់ថ្នាក់សិក្សាយ៉ាងតឹងរឹងនៅគ្រប់សាលារៀនទាំងអស់នៅក្នុងស្រុក/សង្កាត់នោះ មិនត្រឹមតែពី-បីសាលានោះទេ។ ប៉ុន្តែនៅពេលដែលលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញហើយ ស្រុក/សង្កាត់នឹងអាចប្រើប្រាស់ថវិកាមូលនិធិទាំងនេះសម្រាប់បំពេញតម្រូវការសំខាន់ក្នុងស្រុកផ្សេងទៀតដូចជាការសិក្សាអំពីជាតិសាសន៍ និងជំនួយចំពោះអ្នកសិក្សាភាសាអង់គ្លេស។

លើសពីនេះទៀត ខ្ញុំកំពុងស្នើសុំពង្រីកការវិនិយោគរបស់យើងក្នុងសហគមន៍សាលារៀន ដែលធ្វើការជាមួយក្រុមគ្រួសារ, សិស្ស, លោកគ្រូអ្នកគ្រូ និងអង្គការក្នុងសហគមន៍ ដើម្បីកំណត់ឲ្យដឹងពីតម្រូវការដែលមិនទាន់បានបំពេញរបស់ក្រុមគ្រួសារផ្សេងៗ ហើយបន្ទាប់មកបង្កើតផែនការដើម្បីប្រើប្រាស់ធនធានរបស់សហគមន៍ទៅដោះស្រាយតម្រូវការទាំងនេះនៅក្នុងអាគារសាលារៀន ដោយយកសាលារៀនធ្វើជាមជ្ឈមណ្ឌលសហគមន៍។ តាមរយៈការវិនិយោគលើការសហការនេះ សហគមន៍សាលារៀនទាំងនេះនឹងអាចកំណត់ឲ្យដឹងនិងបំពេញនូវតំរូវការរបស់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង រួមទាំងការចូលរួមពីមាតាបិតាទាក់ទងនឹងផ្នែកវប្បធម៌។ ហើយខ្ញុំកំពុងស្នើសុំបង្កើនចំនួនអ្នកជំនាញសុខភាពផ្លូវចិត្តទ្វេដងនៅក្នុងសាលារបស់យើង។ នេះនឹងធ្វើឱ្យសាលារៀនជាច្រើនដែលមានសិស្សជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំងច្រើនអាចជួលអ្នកជំនាញសុខភាពផ្លូវចិត្តដែលមានសមត្ថភាពខ្ពស់អាចធ្វើការជាមួយមនុស្សផ្សេងៗគ្នាស្របតាមផ្នែកវប្បធម៌និងភាសា។

ទំនាក់ទំនង៖ searac@searac.org

SEARAC (សៀរ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្ដោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ SEARAC មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។



SEARAC

# ការចូលរៀននៅមហាវិទ្យាល័យ, លទ្ធភាពអាចបង់ថ្លៃការសិក្សា និងការបញ្ចប់ការសិក្សា

## Joe Biden (D)

ផែនការរបស់ខ្ញុំនឹង៖

- កំណត់គោលដៅផ្តល់ជំនួយបន្ថែមផ្នែកហិរញ្ញវត្ថុដល់បុគ្គលដែលមានប្រាក់ចំណូលទាបនិងបុគ្គលដែលមានប្រាក់ចំណូលមធ្យម ដោយការបង្កើនតម្លៃអតិបរមានៃជំនួយ **Pell Grant** ទ្វេដង, បង្កើនចំនួនជនជាតិអាមេរិកាំងដែលមានប្រាក់ចំណូលមធ្យមឲ្យអាចចូលរួមក្នុងកម្មវិធីនេះដែរ។ ក្នុងនាមជាប្រធានាធិបតី ខ្ញុំក៏នឹងយកចិត្តទុកដាក់ចំពោះជនអន្តោប្រវេសន៍វ័យក្មេងដោយធានាថា **DREAMers** មានសិទ្ធិទទួលបានជំនួយថវិកាបង់ថ្លៃសិក្សា **(Financial Aid)** ប្រសិនបើពួកគេមានលក្ខណៈគ្រប់គ្រាន់ផ្សេងៗទៀតសម្រាប់ជំនួយនោះ។ ហើយខ្ញុំនឹងស្តារឡើងវិញនូវសិទ្ធិរបស់បុគ្គលដែលធ្លាប់ជាប់ពន្ធធានាគារឲ្យទទួលបានជំនួយ **Pell Grant** នេះដែរ។
- នៅក្រោមផែនការរបស់បៃដិន បុគ្គលដែលរកប្រាក់បាន ២៥ ០០០ ដុល្លារឬតិចជាងនេះក្នុងមួយឆ្នាំនឹងមិនជំពាក់ថ្លៃប្រាក់កម្ចីពីសហព័ន្ធលើថ្នាក់បរិញ្ញាប័ត្រឡើយ ហើយក៏នឹងមិនមានការប្រាក់លើប្រាក់កម្ចីទាំងនោះដែរ។
- ធ្វើឱ្យ **MSIs, HBCUs,** និង **TCUs** មានតំលៃសមរម្យសម្រាប់សិស្សរបស់ពួកគេ។ ផែនការរបស់ខ្ញុំនឹងវិនិយោគទឹកប្រាក់ចំនួន ១៨ ពាន់លានដុល្លារជាជំនួយឥតសំណងដល់សាលារៀនរយៈពេលបួនឆ្នាំទាំងនេះ ដែលស្មើនឹងការបង់ថ្លៃសិក្សារហូតដល់ ២ ឆ្នាំសម្រាប់សិស្សដែលមានប្រាក់ចំណូលទាបនិងមធ្យម រួមទាំងសិស្ស **DREAMers** និងនិស្សិតដែលផ្ទេរទៅ **HBCU, TCU, AANAPISI** ឬ **MSI** ផ្សេងទៀតពីមហាវិទ្យាល័យសហគមន៍ដែលមិនបង់ថ្លៃសិក្សា។
- ផ្តល់ការគាំទ្រដើម្បីធ្វើឱ្យតម្លៃរបស់ **MSIs, HBCUs** និង **TCUs** មានភាពប្រសើរឡើង ដោយធ្វើការវិនិយោគថវិកាចំនួន១០ ពាន់លានដុល្លារទៅលើកម្មវិធីនានាសម្រាប់បង្កើនការចុះឈ្មោះចូលរៀន, ការបន្តការសិក្សា និងបង្កើនអត្រាមានការងារធ្វើ។
- ផ្តល់ថវិកាច្រើនជាងមុនបីដង ព្រមទាំងបង្កើតការបង្កើនសមត្ថភាពនិងជំនួយដល់និស្សិតជាអចិន្ត្រៃយ៍សម្រាប់ **MSIs, HBCUs,** និង **TCUs** ក្នុងចំណងជើងទី ៣ **(Title III)** និងចំណងជើងទី ៤**(Title V)** នៃច្បាប់ឧត្តមសិក្សា។ មូលនិធិទាំងនេះដើរតួដូចជាខ្សែជីវិតសម្រាប់ **MSIs, HBCUs,** និង **TCUs** ពីមួយឆ្នាំទៅមួយឆ្នាំ ដោយធានាថានិស្សិតដែលមិនសូវមានឱកាសនឹងទទួលបានជំនួយដើម្បីជោគជ័យ។ រដ្ឋបាលរបស់ខ្ញុំនឹងផ្តល់លុយជាអចិន្ត្រៃយ៍ចំនួន ៧៥០ លានដុល្លារក្នុងមួយឆ្នាំទៅឲ្យថវិកាមូលនិធិរបស់ចំណងជើងទី ៣**(Title III)** និងចំណងជើងទី ៤**(Title V)** ដែលស្មើនឹងប្រាក់ចំណូលចំនួន ៧.៥ ពាន់លានដុល្លារក្នុងរយៈពេល ១០ ឆ្នាំដំបូង។

**ទំនាក់ទំនង៖ searac@searac.org**

**SEARAC** (សៀរ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង **(SEAA)**។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ **SEARAC** មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។



# ការចូលរៀននៅមហាវិទ្យាល័យ, លទ្ធភាពអាចបង់ថ្លៃការសិក្សា និងការបញ្ចប់ការសិក្សា

## Donald Trump (R)

សៀវ៉ាក់ **(SEARAC)** មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។



# ការទទួលបានសេវាថែទាំសុខភាពដែលមានតំលៃសមរម្យ

## Joe Biden (D)

ផែនការរបស់ខ្ញុំនឹងបោះជំហានបន្ថែមទៅលើកម្មវិធី អូបាម៉ាឃែរ ដែលអនុញ្ញាតឱ្យជនជាតិអាមេរិកាំងដែលមិនមានការធានារ៉ាប់រងសុខភាពឬមិនពេញចិត្តនឹងការធានារ៉ាប់រងរបស់ពួកគេ អាចទិញការធានារ៉ាប់រងសាធារណៈដែលមានលក្ខណៈដូចនឹង មេឌីឃែរ (Medicare) ដែរ។ ផែនការរបស់ខ្ញុំក៏បង្កើនឥណទានពន្ធពិសេស (Premium tax credits)ផងដែរ ដូច្នេះមនុស្សកាន់តែច្រើននឹងចេញលុយតិច ហើយនិងចេញថ្លៃផ្ទាល់ខ្លួនតិចពេលទៅពេទ្យ។ ផែនការរបស់ខ្ញុំនឹងជួយដល់ក្រុមគ្រួសារវណ្ណៈកណ្តាលដែលមានប្រាក់ចំណូលមធ្យម ដោយពួកយើងនឹងលុបបំបាត់ការកំណត់ប្រាក់ចំណូល (Income Cap) ៤០០% ទៅលើសិទ្ធិទទួលបានឥណទានពន្ធ (Tax Credit) ព្រមទាំងបន្ថយកំរិតនៃការចំណាយលើការធានារ៉ាប់រងសុខភាពពី ៩.៨៦% នៃប្រាក់ចំណូលមកត្រឹមតែ ៨.៥% ប៉ុណ្ណោះ។ នេះមានន័យថា គ្រប់ក្រុមគ្រួសារនឹងចំណាយមិនលើសពី ៨.៥% នៃប្រាក់ចំណូលរបស់ពួកគេឡើយក្នុងការទិញការធានារ៉ាប់រងសុខភាពនៅលើទីផ្សារ។

ផែនការរបស់ខ្ញុំនឹងធានាថាបុគ្គលដែលមានប្រាក់ចំណូលទាបនឹងទទួលបានការធានារ៉ាប់រងសុខភាពឥតគិតថ្លៃដោយការផ្តល់ជូននូវជម្រើសសាធារណៈសម្រាប់មនុស្សចំនួនប្រហែល ៤ លាននាក់ដែលមានសិទ្ធិទទួលបានកម្មវិធីសុខភាព មេឌីខេត (Medicaid)ប៉ុន្តែរដ្ឋរបស់ពួកគេមិនធ្វើសកម្មភាព ហើយពួកយើងនឹងធ្វើឱ្យប្រាកដថាជម្រើសសាធារណៈរបស់ពួកគេនឹងមានអត្ថប្រយោជន៍ពេញលេញដូចអត្ថប្រយោជន៍របស់កម្មវិធីសុខភាព Medicaid ដែរ។ ចំពោះរដ្ឋដែលបានពង្រីកកម្មវិធីសុខភាព មេឌីខេត (Medicaid) រួចហើយនឹងអាចមានជម្រើសផ្លាស់ប្តូរឲ្យប្រជាជនមកប្រើជម្រើសការធានារ៉ាប់រងសាធារណៈដោយមិនគិតថ្លៃនេះវិញបាន ប្រសិនបើរដ្ឋទាំងនោះនៅតែបន្តបង់ចំណែកថ្លៃធានារ៉ាប់រងទៅលើបុគ្គលទាំងនោះ។ លើសពីនេះទៀត ខ្ញុំនឹងធានាថាប្រជាជនដែលមានប្រាក់ចំណូលក្រោម ១៣៨% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធនឹងមានការធានារ៉ាប់រងសុខភាពដែរ។ ខ្ញុំនឹងធ្វើវាដោយធ្វើការចុះឈ្មោះបុគ្គលទាំងនេះដោយស្វ័យប្រវត្តិនៅពេលពួកគេមកទាក់ទងជាមួយស្ថាប័នជាក់លាក់ណាមួយ (ដូចជាសាលារៀន)ឬជាមួយកម្មវិធីផ្សេងទៀតសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប (ដូចជា ជំនួយម្ហូបអាហារ SNAP)

ខ្ញុំជឿជាក់ថាកម្មវិធីសុខភាព Medicaid ដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់យើងហើយវាត្រូវតែទទួលរក្សាការពារនិងត្រូវបានទទួលថវិកាជំនួយតទៅមុខទៀត។ ក្នុងនាមជាប្រធានាធិបតីខ្ញុំនឹងតស៊ូខិតខំដើម្បីជំនះឧបសគ្គទាំងអស់ដែលរារាំងការទទួលបានកម្មវិធីនេះ ដែលឧបសគ្គទាំងនោះមានដូចជាលក្ខខណ្ឌតឹងរ៉ឹងនិងវិធីកាត់បន្ថយការចុះឈ្មោះប្រជាជនចូលក្នុងកម្មវិធីនេះ។

ទំនាក់ទំនង៖ searac@searac.org

SEARAC (សៀរ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ SEARAC មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។



# ការទទួលបានសេវាថែទាំសុខភាពដែលមានតំលៃសមរម្យ

## Donald Trump (R)

សៀវ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

ទំនាក់ទំនង៖ searac@searac.org

SEARAC (សៀវ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ SEARAC មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។




# សេវាកម្មសុខភាពផ្លូវចិត្តសមស្របតាមវប្បធម៌និងភាសា

## Joe Biden (D)

ក្នុងនាមជាប្រធានាធិបតី ខ្ញុំនឹងធានាថាការអនុវត្តច្បាប់សមភាពនៃសុខភាពផ្លូវចិត្តគឺជាអាទិភាពមួយ។ បច្ចុប្បន្ននេះ រដ្ឋនីមួយៗខុសប្លែកពីគ្នានៅក្នុងរបៀបដែលពួកគេកំណត់អត្ថប្រយោជន៍ចាំបាច់នៃសុខភាពទាក់ទងអំពីសុខភាពផ្លូវចិត្ត។ នៅក្នុងរដ្ឋបាលរបស់ខ្ញុំ យើងនឹងកំណត់ស្តង់ដារច្បាស់លាស់ក្នុងការលើកស្ទួយការព្យាបាលសុខភាពផ្លូវចិត្ត រួមមានសេវាកម្មដែលទាក់ទងនឹងទម្លាប់រស់នៅនិងទម្រង់នៃការថែទាំសុខភាពអាកប្បកិរិយា (Behavioral Health) ផ្សេងទៀត។

ខ្ញុំក៏នឹងពង្រីកកម្មវិធី Affordable Care Act (កម្មវិធីថែទាំដែលមានតំលៃសមរម្យ) ដើម្បីឱ្យប្រាកដថាបុគ្គលដែលមានប្រាក់ចំណូលទាបដែលមានជំងឺផ្លូវចិត្តអាចទទួលបានការធានារ៉ាប់រង។ ការទទួលបានការធានារ៉ាប់រងសុខភាពដែលមានតំលៃសមរម្យដែលរាប់បញ្ចូលទាំងការធានារ៉ាប់រងសុខភាពផ្លូវចិត្តមិនគួរអាស្រ័យទៅលើលេខកូដតំបន់ឬប្រាក់ចំណូលរបស់អ្នកឡើយ។

ហើយដោយសារតែខ្ញុំក៏ចង់ធ្វើឱ្យប្រាកដថា កុមារក៏ទទួលបានការថែទាំសុខភាពផ្លូវចិត្តដែលពួកគេត្រូវការដែរ ដូច្នេះខ្ញុំនឹងធ្វើការវិនិយោគដែលមិនធ្លាប់មានពីមុនមកទៅលើអ្នកជំនាញសុខភាពផ្លូវចិត្តនៅក្នុងសាលារៀន ដើម្បីបង្កើនចំនួនអ្នកជំនាញចិត្តសាស្រ្ត, អ្នកប្រឹក្សាយោបល់, គិលានុបដ្ឋាយិកា, អ្នកធ្វើការសង្គម និងអ្នកជំនាញសុខភាពដទៃទៀតឲ្យធ្វើការនៅក្នុងសាលារបស់យើង ព្រមទាំងបង្កើតដៃគូជាមួយមហាវិទ្យាល័យដើម្បីពង្រីកប្រព័ន្ធអ្នកជំនាញផ្លូវចិត្តទាំងនេះ។ ផែនការរបស់ខ្ញុំនឹងអនុញ្ញាតឱ្យសាលារៀនក្នុងស្រុក/សង្កាត់ដែលមានសិស្សជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំងច្រើនជួលអ្នកជំនាញខាងសុខភាពផ្លូវចិត្តដែលមានសមត្ថភាពខ្ពស់អាចធ្វើការជាមួយមនុស្សផ្សេងៗគ្នាស្របតាមផ្នែកវប្បធម៌និងភាសា។

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

ទំនាក់ទំនង៖ searac@searac.org

SEARAC (សៀរ៉ាក់) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ SEARAC មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។



# កម្មវិធីរដ្ឋាភិបាលដើម្បីជួយដល់គ្រួសារដែលមានប្រាក់ចំណូលទាប

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

## Joe Biden (D)

“ក្នុងនាមជាប្រធានាធិបតី ខ្ញុំនឹងបង្កើនថវិកាសម្រាប់កម្មវិធីនេះនិងបង្វែរសកម្មភាពរបស់ប្រធានាធិបតី ត្រាំ **Trump** ដែលគាត់បានដាក់កំណត់កម្មវិធីជំនួយម្ហូប **SNAP** នេះ។ អ្នកដែលទទួលបានជំនួយម្ហូប **SNAP** គួរតែមានជំរើសច្រើនក្នុងការទិញម្ហូបអាហារដូចមនុស្សដទៃទៀតដែរ ហើយពួកគេមិនគួរត្រូវបានគេបង្ខំឱ្យប្រើជម្រើសណាមួយឡើយ។ ក្នុងនាមជាប្រធានាធិបតី ខ្ញុំនឹងជំទាស់នឹងសំណើណាមួយដូចជាគម្រោងប្រអប់ម្ហូបរបស់លោកប្រធានាធិបតី ត្រាំ **(Trump)** ដែលរឹតត្បិតជម្រើសរបស់អ្នកដែលប្រើប្រាស់ជំនួយម្ហូប **SNAP** ។ ហើយខ្ញុំនឹងដោះស្រាយបញ្ហាកន្លែងគ្មានម្ហូបសុខភាព **(food deserts)** ដូច្នេះប្រជាជននៅក្នុងសហគមន៍ដែលមានប្រាក់ចំណូលទាបមិនត្រូវបានបង្ខំឱ្យជ្រើសរើសទិញម្ហូបតែតាមអឺនធឺណែតនោះទេ។ ដើម្បីការពារជំនួយប្រាក់ចំណូលនិងបង្កើនការងារនិងឱកាស ខ្ញុំនឹងរក្សាការពារនិងបង្កើនប្រាក់ជំនួយសន្តិសុខបន្ថែម **(SSI)** និងការធានារ៉ាប់រងពិការភាពសន្តិសុខសង្គម **(SSDI)** ដែលមនុស្សរាប់លាននាក់ពឹងផ្អែកលើវាដើម្បីជីវិតរស់នៅរបស់ពួកគេ។”

**ទំនាក់ទំនង៖ searac@searac.org**

**SEARAC** (សៀរ៉ាក) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ **SEARAC** មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។




# បញ្ចប់ការឃុំខ្លួននិងការនិរទេសទៅប្រទេសកំណើតវិញដោយអយុត្តិធម៌

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

## Joe Biden (D)

ខ្ញុំនឹងបញ្ចប់ការឃុំឃាំងដែលអូសបន្លាយពេលយូរ និងបង្កើតឡើងវិញនូវកម្មវិធីគ្រប់គ្រងករណី (Case Management Program)។ ខ្ញុំនឹងរៀបចំការការពារកុមារដើម្បីប្រាកដថាការមើលថែទាំពួកគេគឺស្របទៅតាមចំណាប់អារម្មណ៍របស់ពួកគេ ហើយខ្ញុំនឹងវិនិយោគលើកម្មវិធីគ្រប់គ្រងករណីរបស់សហគមន៍ រួមទាំងរបស់អង្គការជំនឿសាសនា មានដូចជាអង្គការអន្តោប្រវេសន៍លូថេរ៉ាននិងសេវាកម្មជនភៀសខ្លួន (Lutheran Immigration and Refugee Services) ដើម្បីបញ្ជូនជនចំណាកស្រុកទៅកន្លែងមានសុវត្ថិភាពយ៉ាងឆាប់រហ័ស។ ខ្ញុំក៏នឹងបញ្ចប់ការប្រើប្រាស់មជ្ឈមណ្ឌលឃុំឃាំងដែលរកប្រាក់ចំណេញ ពីព្រោះគ្មានអាជីវកម្មណាគួរទទួលបានផលចំណេញពីការរងទុក្ខរបស់មនុស្សអស់សង្ឃឹមដែលរត់គេចចេញពីអំពើហឹង្សាឡើយ។ ខ្ញុំនឹងថាធានាកន្លែងនានាដែលឲ្យជនអន្តោប្រវេសន៍ជ្រកកោនបណ្តោះអាសន្នមានស្តង់ដារនៃការថែទាំខ្ពស់បំផុត និងផ្តល់អាទិភាពដល់សុវត្ថិភាពនិងសេចក្តីថ្លៃថ្នូររបស់គ្រួសារទាំងនោះជាងអ្វីផ្សេងទៀត។ ហើយខ្ញុំនឹងបញ្ជាក់ឲ្យច្បាស់ថារដ្ឋាភិបាលសហព័ន្ធមិនគួរប្រើកន្លែងឯកជនសម្រាប់ធ្វើការឃុំខ្លួនណាមួយឡើយរួមទាំងការឃុំខ្លួនជនអន្តោប្រវេសន៍ឥតច្បាប់ផងដែរ។

លើសពីនេះទៀត ការដែលចាប់បញ្ជូនមនុស្សដែលមិនដែលត្រូវបានគេផ្តន្ទាទោសពីបទឧក្រិដ្ឋព្រហ្មទណ្ឌធ្ងន់ធ្ងរ និងអ្នកដែលបានរស់នៅ, ធ្វើការ និងរួមចំណែកដល់សេដ្ឋកិច្ចនិងសហគមន៍របស់យើងអស់រយៈពេលជាច្រើនទសវត្សមកហើយ គឺជានិយមន័យនៃភាពមិនរីកចម្រើន។ ខ្ញុំនឹងខិតខំប្រឹងប្រែងដឹកនាំការអនុវត្តច្បាប់ទៅលើជនដែលបង្កភាពអសុវត្ថិភាពសាធារណៈនិងអសន្តិសុខជាតិ ស្របពេលដែលខ្ញុំក៏ត្រូវធានាថាបុគ្គលនីមួយៗត្រូវបានគេគោរពសិទ្ធិតាមនីតិវិធីត្រឹមត្រូវ ហើយការពារសិទ្ធិមនុស្សរបស់ពួកគេ។ ខ្ញុំនឹងបញ្ចប់ការវាយប្រហារនៅកន្លែងធ្វើការ ដើម្បីធានាថាការភ័យខ្លាចដោយសារតែស្ថានភាពអន្តោប្រវេសន៍របស់អ្នកធ្វើការនឹងមិនធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពក្នុងការរៀបចំនិងការឡើងប្រាក់ខែ ព្រមទាំងលក្ខខណ្ឌការងាររបស់ពួកគេឡើយ។ ខ្ញុំក៏នឹងការពារទីតាំងដែលងាយរងគ្រោះ (Sensitive Locations) ពីសកម្មភាពអនុវត្តច្បាប់អន្តោប្រវេសន៍ផងដែរ។

ទំនាក់ទំនង៖ searac@searac.org

SEARAC (សៀរ៉ាក់) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ SEARAC មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។



# ពង្រឹងកម្មវិធីទាក់ទងនឹងការចូលសញ្ជាតិ

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

## Joe Biden (D)

“ រដ្ឋបាលរបស់ខ្ញុំនឹងសម្រួលដំណើរការចូលសញ្ជាតិ និងធ្វើឲ្យវាកាន់តែប្រសើរឡើង ដើម្បីឲ្យមានភាពងាយស្រួលដល់អ្នកដែលមានគ្រីនកាត (Green Card) ក្នុងការចូលសញ្ជាតិ។ ខ្ញុំនឹងស្តារសេចក្ដីទុកចិត្តលើដំណើរការចូលសញ្ជាតិ ដោយការបំបាត់ឧបសគ្គរារាំងការចូលសញ្ជាតិ និងការទទួលបានសិទ្ធិបោះឆ្នោត ព្រមទាំងដោះស្រាយភាពយឺតយ៉ាវ ដោយផ្តល់អាទិភាពដល់ចរន្តការងារវិនិច្ឆ័យ និងធានាថាពាក្យសុំត្រូវបានដំណើរការយ៉ាងឆាប់រហ័ស ហើយលុបចោលការយកថ្លៃមួយចំនួនដែលមិនសមហេតុផល។

ក្នុងនាមជាប្រធានាធិបតី ខ្ញុំនឹងយកចិត្តទុកដាក់បន្ថែមទៅលើធនធានសហព័ន្ធ តាមរយៈការបង្កើតឡើងវិញនូវក្រុមការងារសម្រាប់ប្រជាជនអាមេរិកថ្មី (Task Force for New Americans) ដើម្បីគាំទ្រដល់ការខិតខំរបស់សហគមន៍ក្នុងការស្វាគមន៍ជនអន្តោប្រវេសន៍។ ការខិតខំប្រឹងប្រែងជាក់ស្តែងនឹងកើតមានជាញឹកញាប់នៅតាមសហគមន៍នីមួយៗ ប៉ុន្តែទីភ្នាក់ងាររបស់សហព័ន្ធមានព័ត៌មាននិងធនធានយ៉ាងច្រើនសម្រាប់គាំទ្រដល់ការខិតខំប្រឹងប្រែងរបស់សហគមន៍ទាំងនោះ។ តាមរយៈការអនុម័តតាមគំនិតផ្តួចផ្តើមដែលទទួលបានការជ្រោមជ្រែងដោយអង្គការដូចជា **Welcoming America** រដ្ឋបាលរបស់ខ្ញុំនឹងធ្វើឱ្យការចូលដំណើរការទៅទីភ្នាក់ងារសហព័ន្ធកាន់តែប្រសើរឡើង ព្រមទាំងគាំទ្រដល់គំនិតផ្តួចផ្តើមក្នុងតំបន់ដូចជា៖

- បង្កើតមជ្ឈមណ្ឌលធនធានក្នុងតំបន់ ឬមជ្ឈមណ្ឌលស្វាគមន៍ ដើម្បីជួយប្រជាជនទាំងអស់ក្នុងការស្វែងរកការងារធ្វើ, ទទួលបានសេវាកម្មនិងឱកាសរៀនភាសាអង់គ្លេស, ព្រមទាំងណែនាំអំពីប្រព័ន្ធអប់រំ ប្រព័ន្ធថែទាំសុខភាព និងផ្នែកសំខាន់ៗផ្សេងទៀតនៃជីវិតប្រចាំថ្ងៃ។
- បើកយុទ្ធនាការជួយអ្នកដែលមានសិទ្ធិរស់នៅស្របច្បាប់ក្នុងការចូលសញ្ជាតិ។
- ធានាថាសាលារដ្ឋទាំងអស់ផ្តល់ជំនួយក្នុងការរៀនភាសាអង់គ្លេសឱ្យបានគ្រប់គ្រាន់ ដើម្បីជួយកុមារទាំងអស់ឱ្យឈានដល់សក្តានុពលរបស់ពួកគេ។ ”

ទំនាក់ទំនង៖ searac@searac.org

**SEARAC** (សៀរ៉ាក់) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ **SEARAC** មិនគាំទ្រឬប្រឆាំងបេក្ខជនមួយណាទេ។



# ការពារនិងពង្រីកការធ្វើអន្តោប្រវេសន៍ជាគ្រួសារ

## Joe Biden (D)

“ ក្នុងនាមជាប្រធានាធិបតី ខ្ញុំនឹងគាំទ្រដល់ការធ្វើអន្តោប្រវេសន៍ជាគ្រួសារដោយយកការថែរក្សាភាពរួបរួមគ្រួសារជាគ្រឹះនៃប្រព័ន្ធអន្តោប្រវេសន៍របស់យើង, ដោយអនុញ្ញាតឱ្យអ្នកដែលគេយល់ព្រមឲ្យមកទទួលទិដ្ឋាការមិនមែនអន្តោប្រវេសន៍បណ្តោះអាសន្នសិនរហូតដល់ពេលទិដ្ឋាការអចិន្ត្រៃយ៍ត្រូវបានដំណើរការ, និងដោយគាំទ្រច្បាប់ដែលចាត់ទុកប្តីប្រពន្ធនិងកូនរបស់អ្នកមានគ្រីនកាត (Green Card) ជាសាច់ញាតិជិត (Immediate Relatives) ដែលអាចធានាឲ្យមករស់នៅដោយមិនមានចំនួនកំណត់ និងអនុញ្ញាតឱ្យឪពុកម្តាយយកកូនតូចៗរបស់ពួកគេមកជាមួយនៅពេលពួកគេចំណាកស្រុកមករស់នៅអាមេរិក។

សហរដ្ឋអាមេរិចត្រូវបានពង្រឹងវិស័យវប្បធម៌និងសេដ្ឋកិច្ចតាមរយៈជនអន្តោប្រវេសន៍និងជនភៀសខ្លួនមកពីបណ្តាប្រទេសនានានៅអាស៊ីអាគ្នេយ៍ដែលបានមករស់នៅសហរដ្ឋអាមេរិក។ ការផ្តល់ក្តីសង្ឃឹមនិងទីជម្រកសុវត្ថិភាពដល់ជនភៀសខ្លួនគឺជាកាតព្វកិច្ចយើងដែលជាប្រទេសមួយ ដែលជាមូលហេតុដែលខ្ញុំនឹងប្រកាន់ខ្ជាប់នូវតម្លៃស្នូលដែលបានធ្វើឱ្យយើងក្លាយជាយើងនាពេលសព្វថ្ងៃ ហើយយើងនឹងផ្តល់អាទិភាពដល់ការទទួលយកជនភៀសខ្លួន ស្របតាមការអនុវត្តតាមប្រវត្តិសាស្ត្ររបស់យើងស្របតាមទាំងរដ្ឋបាលបក្សប្រជាធិបតេយ្យនិងរដ្ឋបាលបក្សសាធារណរដ្ឋ។ ខ្ញុំនឹងកំណត់ការទទួលជនភៀសខ្លួនជាសកលរហូតដល់ចំនួន ១២៥ ០០០ នាក់ក្នុង១ឆ្នាំ ហើយនឹងព្យាយាមបង្កើនចំនួននេះថែមទៀតតាមពេលវេលាសមស្របទៅនឹងការទទួលខុសត្រូវរបស់ពួកយើង, តម្លៃរបស់ពួកយើង, និងតម្រូវការពិភពលោកផ្សេងៗដែលមិនធ្លាប់មានពីមុនមក។ ”

## Donald Trump (R)

សៀរ៉ាក់ (SEARAC) មិនបានទទួលការឆ្លើយតបពីយុទ្ធនាការរបស់លោកត្រាំទេ។

ទំនាក់ទំនង៖ searac@searac.org

**SEARAC** (សៀរ៉ាក់) បានអញ្ជើញអ្នកធ្វើយុទ្ធនាការឃោសនាសម្រាប់អ្នកឈរឈ្មោះធ្វើប្រធានាធិបតីនីមួយៗ ដើម្បីឆ្លើយតបទៅនឹងសំណួរដូចៗគ្នាដែលត្រូវបានបង្កើតឡើងស្របតាមពីរបៀបវារៈ និងគោលនយោបាយសមភាព ផ្តោតទៅលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ជនជាតិអាស៊ីអាគ្នេយ៍អាមេរិកាំង (SEAA)។ យើងធ្វើបទបង្ហាញដែលដកស្រង់ពីចម្លើយរបស់ពួកគេគ្រប់ពាក្យ។ ការិយាល័យសាធារណៈ **SEARAC** មិនគាំទ្របុប្រឆាំងបេក្ខជនមួយណាទេ។